អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA

# ដំណឹងជ្រើសរើសបុគ្គលិក

## តួនាទី៖ អ្នកយាមការិយាល័យ

អង្គការ អាយស៊ីស៊ី ជាអង្គការអភិវឌ្ឍន៍គ្រីស្ទបរិស័ទដែលមានលក្ខណៈច្នៃប្រឌិត ប្តេជ្ញាចិត្តបម្រើអ្នកដែលត្រូវបានគេយកចិត្តតិចតួច ក្នុងព្រះរាជាណាចក្រកម្ពុជា

**អង្គការអាយស៊ីស៊ី គម្រោងអប់រំ និងអភិវឌ្ឍន៍សហគមន៍ផ្អែកលើអត្តសញ្ញាណ** (អាយប៊ីស៊ីឌីអី) ធ្វើការផ្ទាល់ និងមិនផ្ទាល់ជាមួយសហគមន៍ជនជាតិដើមភាគតិច ក្នុងគោលបំណងចង់ឃើញ សហគមន៍មានសេចក្តីថ្លៃថ្នូរ និងផ្តត់គំនិតដែលអាចជួយខ្លួនឯង ឲ្យសម្របខ្លួនទៅនឹងបរិបទដែលកំពុងផ្លាស់ប្តូរ ទទួលបានសិទ្ធិពេញលេញ និងចូលរួមជាកោសិកាសង្គមកម្ពុជាដែលមានគុណតម្លៃ និងសកម្ម។ អង្គការ ត្រូវការជ្រើសរើសបុគ្គលិកធ្វើការពេញម៉ោងចំនួន **០២នាក់** ជាបុរស ដើម្បីបំពេញតួនាទី«**អ្នកយាមការិយាល័យ** »។

<u>ទីកន្លែងធ្វើការ៖</u> **ខេត្តរតនគិរី**

**<u>បែបបទការងារ</u>**

- តួនាទីការងារនេះ តម្រូវឲ្យយាមពេញ ២៤ម៉ោង (ថ្ងៃ និងយប់) រយៈពេល២សប្តាហ៍ក្នុងមួយខែ ដោយមានផ្លាស់វេនគ្នា។
- តួនាទីការងារនេះ តម្រូវឲ្យមានការទំនួលខុសត្រូវខ្ពស់ មើលថែរក្សាសុវត្ថិភាព និងសម្ភារៈបរិក្ខារផ្សេងៗរបស់អង្គការដែលមាននៅបរិវេនការិយាល័យ។

**<u>លក្ខណៈសម្បត្តិ និងតម្រូវការ</u>**

- ចេះនិយាយ ចេះអាន និងចេះសរសេរភាសាខ្មែរយ៉ាងតិចរៀនចប់ត្រឹមថ្នាក់ទី៩ ។
- មានអាកប្បកិរិយាទន់ភ្លន់ ស្លៀកពាក់សមរម្យ និងចេះទទួលរាក់ទាក់ភ្ញៀវ ។
- មានគំនិតផ្តួចផ្តើម អាចធ្វើការដោយខ្លួនឯង ((ឯករាជ្យ) និងធ្វើការជាក្រុម ។
- មានការទទួលខុសត្រូវក្នុងការងារ លះបង់ពេលវេលា និងចេះបត់បែន ។
- ស្មោះត្រង់ និងមានតម្លាភាពក្នុងការទទួលខុសត្រូវតួនាទីរបស់ខ្លួន ។
- មានទឹកចិត្តចូលរួមជួយការងារបុគ្គលិកដូចជា លើក និងទុកដាក់សម្ភារៈនានានៅពេលទៅ ឬមកពីភូមិវិញ។
- មានឆន្ទៈស្រលាញ់ការងារអភិវឌ្ឍន៍សហគមន៍ ដោយគ្មានការរើសអើង (ជនពិការ សាសនា ពូជសាសន៍ និងនិន្នាការនយោបាយ...)។
- មានគំរូល្អក្នុងការដឹកនាំ (ក្នុងគ្រួសារ និងក្រុមការងារ)
- គោរពស្រលាញ់វប្បធម៌ជនជាតិដើមភាគតិច ព្រមទាំងមានចិត្តចង់ចូលរួមអភិវឌ្ឍន៍ អភិរក្សសម្បត្តិវប្បធម៌ របស់ជនជាតិដើមភាគតិចឲ្យនៅគង់វង្ស។

ការដាក់ពាក្យ

បេក្ខជនដែលចាប់អារម្មណ៍ សូមដាក់**ពាក្យស្នើសុំ** និងប្រវត្តិរូបសង្ខេប១ច្បាប់ មិនឲ្យលើសពី**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨** វេលាម៉ោង ៥ៈ០០ល្ងាច នៅការិយាល័យអង្គការអាយស៊ីស៊ីខេត្តរតនគិរីដែលមានអាសយដ្ឋាន ភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ទូរសព្ទលេខ ០៩៧ ២១៦ ១៦៩០ ឬ ផ្ញើរតាមរយៈអ៊ីម៉ែល admin.ibcde@icc.org.kh

ទម្រង់ពាក្យស្នើសុំ អាចទាញយកបាន តាមរយៈគេហទំព័រ http://www.icc.org.kh/opportunities.php ឬ មកទទួលយកទម្រង់ពាក្យស្នើសុំតាមអាសយដ្ឋានបញ្ជាក់ខាងលើ។

មានតែបេក្ខជនដែលត្រូវបានជ្រើសរើសឲ្យមកសម្ភាសន៍ប៉ុណ្ណោះ នឹងត្រូវបានទាក់ទង។ បេក្ខជនដែលទទួលបានជោគជ័យ នឹងតម្រូវឲ្យគោរពឲ្យបានពេញលេញ តាមក្បួនច្បាប់គោលនយោបាយបុគ្គលិកជាតិ ក៏ដូចជាគោលនយោបាយការពារកុមាររបស់អង្គការអាយស៊ីស៊ី។